# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ១២៥២ អ.ក
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០
សាលក្រមលេខ ០៤០ ស.ព្រ.ណ/២០
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល ។
កាលបរិច្ឆេទសវនាការ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ។
កាលបរិច្ឆេទនៃការប្រកាសសាលក្រមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១២៥២ អ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] ចិប ភេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ រៀនថ្នាក់ទី៥ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្ដាល និង ទីលំនៅបច្ចុប្បន្ននៅភូមិទេពអរជូន ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] **ចឹក** (រស់) ម្ដាយឈ្មោះ [redacted] **ហ៊ីង** (ស្លាប់) ទោសពីមុខគ្មាន ។

ត្រូវបានជាប់ចោទពី **បទរំលោភការកាន់កាប់អចលនវត្ថុអ្នកដទៃ** ប្រព្រឹត្តនៅភូមិទេពអរជូន ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

មេធាវីឈ្មោះ [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចិប ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គិត ភេទប្រុស កើតឆ្នាំ១៩៨៧ ទីលំនៅបច្ចុប្បន្ននៅភូមិទេពអរជូន ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ។

- **បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ។

### អង្គហេតុដែលបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះ

កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ នៅភូមិទេពអរជូន ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ឈ្មោះ [redacted] ចិប បានធ្វើសកម្មភាពសង់របងថ្មចូលទៅក្នុងដីរបស់ឈ្មោះ [redacted] គិត ប្រវែង ៤,៥ តឹក ដែលដី

នេះមានទំហំសរុប ៣អា ២០,៣២ សង់ទីអា ហើយជាដីដែលបានកាន់កាប់ដោយឈ្មោះ[redacted]មឿន ត្រូវជាម្តាយមីងរបស់ឈ្មោះ [redacted]គិត តាមប័ណ្ណសម្គាល់សិទ្ធិលេខ Dᴃ 0232 ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៣ ។ ក្រោយមកឈ្មោះ [redacted]គិត បានប្តឹងទៅអាជ្ញាធរភូមិឃុំឱ្យចុះមកវាស់វែងជាក់ស្តែង ដោយឈ្មោះ[redacted]ចិប ក៏បានព្រមព្រៀងថាខ្លួននឹងវាយរបងនោះចេញ ប្រសិនបើការវាស់វែងជាក់ស្តែងឃើញថាខ្លួនពិតជាបានសង់របងចូលព្រំដីនោះមែន ហើយបន្ទាប់ពីការវាស់វែងជាក់ស្តែងឃើញថាឈ្មោះ [redacted] ចិប ពិតជាបានសង់របងចូលដីខាងលើនេះប្រាកដមែន ។

## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

១. ជនជាប់ចោទឈ្មោះ [redacted] ចិប បានឆ្លើយនៅចំពោះមុខតុលាការថា ការសាងសង់នោះមានការយល់ព្រមពីដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែក្រោយចាក់ថ្នឹមស្រាប់តែគាត់ប្តឹងថាសាងសង់ក្នុងដីគាត់ទៅវិញ ការសាងសង់របងនោះក្នុងដីជាកម្មសិទ្ធិរបស់ខ្ញុំប៉ុណ្ណោះ ។

២. សាក្សីឈ្មោះ[redacted]រឿន ភេទប្រុស អាយុ ៦០ឆ្នាំ បានឆ្លើយបំភ្លឺថា ខ្ញុំជាជាងសំណង់ធ្វើរបងឱ្យឈ្មោះ [redacted]ចិប ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឯកភាពឱ្យខ្ញុំធ្វើរបងនោះ ។

៣. សាក្សីឈ្មោះ [redacted]គ្រិន ភេទប្រុស អាយុ ៤០ឆ្នាំ បានឆ្លើយបំភ្លឺថា ដើមបណ្តឹងរដ្ឋប្បវេណីបានឯកភាពឱ្យពួកខ្ញុំជាជាងសំណង់ធ្វើការសង់របងនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានជួយទាញខ្សែរម៉ែត្រវាស់ទៀតផង ។

៤. អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]គិត (សង្ខេប) ៖ ឈ្មោះ [redacted] ចិប បានសង់របងចូលដីខ្ញុំទំហំ ៤,៥ តឹក បណ្តោយ ១៣ ម៉ែត្រ ដោយមុនពេលសាងសង់ក៏មានអាជ្ញាធរភូមិ ឃុំ ចុះមកវាស់វែង ភាគីមានការឯកភាពគ្នាធ្វើកិច្ចសន្យាដែរ បើលើសរុះរើរបងចោល ។ តែនៅពេលវាស់ជាក់ស្តែងឃើញថាឈ្មោះ[redacted]ចិប ធ្វើរបងចូលដីខ្ញុំប្រវែង ៤,៥ តឹក ហើយមិនព្រមរុះរើរបងនោះទេ ។

៥. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ជនជាប់ចោទបានសាងសង់របងពិតប្រាកដមែន ប៉ុន្តែការសាងសង់នោះមានការឯកភាពពីដើមបណ្តឹងរដ្ឋប្បវេណី ហើយដីនោះមិនទាន់មានប័ណ្ណកម្មសិទ្ធិទេ ។ ដូចនេះតំណាងអយ្យការប្តឹងសុំឱ្យជនជាប់ចោទ រួចខ្លួនពីបទចោទ ។

៦. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យកូនក្តីរួចខ្លួនពីបទចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងលើសំណុំរឿងនេះ



Scanned with CamScanner

## សំអាងហេតុ

១. យោងតាមចម្លើយសារភាពរបស់ជនជាប់ចោទនៅពេលពិភាក្សាដេញដោល និង ចម្លើយរបស់សាក្សី អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ចិប មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយមុនពេលជនជាប់ចោទសាងសង់របងក៏មានការសុំអនុញ្ញាតពីដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏មានការឯកភាពផងដែរ ។ ដូចនេះតុលាការយល់ឃើញថា មិនមានការរំលោភការកាន់កាប់អចលនវត្ថុអ្នកដទៃទេ ដោយមានចម្លើយសារភាព និង ភស្តុតាងស៊ីសង្វាក់គ្នា ។

២. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ប្ដឹងសុំឱ្យជនជាប់ចោទរួចខ្លួនពីបទចោទ ដោយតាមភស្តុតាងមានភាពស៊ីចង្វាក់គ្នា អាចបញ្ជាក់បានថាជនជាប់ចោទ មិនបានប្រព្រឹត្តបទល្មើសនោះទេ។

៣. បន្ទាប់ពីឆ្លងកាត់ការពិភាក្សាដេញដោល និង ការពិនិត្យនូវភស្តុតាងនានាក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ចិប មិនបានប្រព្រឹត្តបទរំលោភកាន់កាប់អចលនវត្ថុអ្នកដទៃ នៅភូមិទេពអរជូន ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា **២៥៣** នៃច្បាប់ភូមិបាល ដូចការចោទប្រកាន់ខាងលើនោះទេ ។

## ហេតុដូច្នេះសម្រេច

ឱ្យឈ្មោះ [redacted] ចិប ភេទប្រុស អាយុ ៥០ឆ្នាំ រួចខ្លួនពី**បទរំលោភការកាន់កាប់អចលនវត្ថុអ្នកដទៃ** ប្រព្រឹត្តនៅភូមិទេពអរជូន ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា **២៥៣** នៃច្បាប់ភូមិបាល ។

សាលក្រមនេះ ចំពោះមុខជនជាប់ចោទ និង កំបាំងមុខដើមបណ្ដឹង ។ បើកសិទ្ធិប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍ តាមនីតិវិធីច្បាប់។

ថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្ដាល, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

| **ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និង ត្រា [redacted] | ហត្ថលេខា និង ត្រា [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្ដាល, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

| បានឃើញ<br>**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
|---|---|
| [redacted] | [redacted] |